ទីស្តីការក្រសួងយុត្តិធម៌

លេខ ២០៦ សច-ព្រទ-៩៥

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### ផ្ញើចាប់ចក

លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង និងអមតុលាការយោធា
លោកប្រធានតុលាការខេត្ត ក្រុង និងតុលាការយោធា

**សូមជ្រាប។**

**កម្មវត្ថុ:** កំណត់ស្តីពីវិធីចោទប្រកាន់ទាំងឡាយលើបទល្មើសដោយអយ្យការ ។

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថាការងាររបស់តុលាការកាន់តែគរច្រើនឡើងៗ ដោះស្រាយមិនទាន់ពេល និងមិនឆ្លើយតបបានតាមសំណូមពររបស់ប្រជាជន ។

ការយឺតយ៉ាវនេះ ពាក់ព័ន្ធនឹងរឿងរដ្ឋប្បវេណីក៏ដូចជារឿងព្រហ្មទណ្ឌ ។

ចំពោះរឿងព្រហ្មទណ្ឌ ចំណែកមួយដែលធ្វើអោយមានការយឺតយ៉ាវ គឺការចំណាយពេលដ៏ច្រើនដើម្បីបង្កសំណុំរឿងជូនទៅតុលាការ ដែលបណ្តាលមកពីព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យចៅក្រមស៊ើបសួរសឹងតែគ្រប់រឿងព្រហ្មទណ្ឌទាំងអស់ ។

ខ្ញុំសូមរំលឹកអស់លោកអំពីវិធីចោទប្រកាន់ និងការជ្រើសរើសវិធីចោទប្រកាន់ដូចតទៅនេះ៖

**I-អំពីវិធីចោទប្រកាន់**

ការធ្វើបណ្តឹងអាជ្ញាជាភារកិច្ចរបស់ព្រះរាជអាជ្ញា ។ ដើម្បីធ្វើបណ្តឹងអាជ្ញាមធ្យោបាយចោទប្រកាន់មានដូចខាងក្រោម មាត្រា ១០២ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ៖

-ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

-ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ

-ការនាំខ្លួនជនជាប់ចោទទៅកាន់សវនាការជំនុំជម្រះភ្លាម ក្នុងករណីបទល្មើសមជ្ឈិមជាក់ស្តែង ។

**១-ការបញ្ជូនទៅជំនុំជម្រះផ្ទាល់៖**

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាវិធីមួយដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់បញ្ជូនជនជាប់ចោទទៅមុខតុលាការដោយផ្ទាល់តែម្តង ។

តាមមាត្រា ៦៧ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាអាចនឹងប្រើវិធីនេះបានកាលបើជនជាប់ចោទត្រូវទទួលទោសដាក់ពន្ធនាគារដែលអតិបរមានៃទោសមិនលើសពី១ ឆ្នាំ។ ក្នុងចំណោមបទល្មើសមជ្ឈិមដែលមានចែងនៅក្នុងបទបញ្ញត្តិព្រហ្មទណ្ឌអន្តរកាល និងច្បាប់ផ្សេងៗទៀត ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគា ហើយដែលអតិបរមានៃទោសមិនលើសពី១ឆ្នាំ គឺមានជាអាទិ៍៖

-បទល្មើសបង្ករបួសស្នាមដែលមិនបណ្តាលឱ្យបាត់បង់សមត្ថភាពពលកម្ម ( មាត្រា ៨១ ) ។

-ការញុះញង់អោយធ្វើការរើសអើង ( មាត្រា ៦១ ) ។

-ការបរិហារកេរ្តិ៍ និងការជេរប្រមាថ ( មាត្រា ៦៣ ) ។

-ការប្រើគ្រឿងញៀន ( មាត្រា ៦៥ ) ។

-បទល្មើសរត់គេចខ្លួនក្រោយពេលគ្រោះថ្នាក់ចរាចរ ( មាត្រា ៥៩ ច្បាប់ចរាចរផ្លូវគោក ។

-បទល្មើសបង្ករបួសស្នាមដោយអចេតនា ( មាត្រា ៥៦ ច្បាប់ចរាចរផ្លូវគោក )។

-បទល្មើសដទៃទៀតដែលមានចែងក្នុងច្បាប់ជលផល រុក្ខាប្រម៉ាញ់ គយ ពន្ធដារ នឹងច្បាប់ពលកម្ម ក៏អាចត្រូវបានចោទប្រកាន់ដោយវិធីជូនទៅជំនុំជម្រះផ្ទាល់នេះបានដែរ ។

**<u>២-សេចក្តីសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរៈ</u>**

ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ គឺជាលិខិតលាយល័ក្ខអក្សររបស់ព្រះរាជអាជ្ញាដែលប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបអង្កេតអំពីរឿងទាំងឡាយជាកំណត់ (មាត្រា ៦០ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌចែងថាព្រះរាជអាជ្ញាបើកអោយធ្វើការស៊ើបសួរភ្លាមតាមសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប្រសិនបើជាបទឧក្រិឋ្ឋបទមជ្ឈឹម

មាត្រា ៦១ បានបញ្ជាក់ថាចំពោះបទមជ្ឈឹម ព្រះរាជអាជ្ញាអាចធ្វើការជ្រើសរើសដោយបើកឱ្យធ្វើការស៊ើបសួរឬក៏បញ្ជូនទៅជំនុំជម្រះផ្ទាល់តែម្តងប្រសិនបើមានគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៦៧ ។

ចំពោះរឿងឧក្រិដ្ឋការធ្វើការស៊ើបអង្កេតតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាការចាំបាច់។ឯបទមជ្ឈឹមការស៊ើបសួរចាំបាច់ត្រូវតែធ្វើដោយខានពុំបាន គឺចំពោះតែបទល្មើសមជ្ឈឹមណាដែលត្រូវផ្តន្ទាទោសជាប់ពន្ធធាគារលើសពី១ឆ្នាំ ហើយដែលមិនមែនជាបទល្មើសមជ្ឈឹមជាក់ស្តែងតែប៉ុណ្ណោះ ពីព្រោះថាមានរួចទៅហើយនូវនីតិវិធីពិសេសមួយដែលអនុញ្ញាតអោយជំនុំជម្រះភ្លាមនូវបទល្មើសមជ្ឈឹមជាក់ស្តែង ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។

ចំពោះបទល្មើសមជ្ឈឹម ដែលមានកម្រិតទោសពន្ធនាគារតិចជាង ១ ឆ្នាំ ដែលមានកំណត់ហេតុធ្វើដោយភ្នាក់ងារនគរបាលយុត្តិធម៌ ប៉ុន្តែមិនទាន់មានភស្តុតាងគ្រប់គ្រាន់ទៅលើសហចារី ឬជនសមគំនិត ក៏ត្រូវសុំទៅចៅក្រមស៊ើបសួរឱ្យធ្វើការស៊ើបអង្កេតដែរ ប្រសិនបើបទល្មើសមជ្ឈឹមនោះមានទំនាក់ទំនង ជាមួយបទល្មើសអាជ្ញាផ្សេងទៀតដែលមិនទាន់មានភស្តុតាងគ្រប់គ្រាន់អាចឱ្យបញ្ជូនទៅតុលាការជំនុំជម្រះជាមួយគ្នាបាន ។

**<u>៣-ការនាំខ្លួនជនជាប់ចោទទៅកាន់សវនាការភ្លាមក្នុងករណីបទល្មើសមជ្ឈឹមជាក់ស្តែង</u>**

នីតិវិធីនេះ ដែលមានចែងក្នុងមាត្រា ១០២ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ត្រូវបានកំណត់ដោយមាត្រា ៦៣ ដល់ ៦៦ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌនេះ ។

នីតិវិធីនេះ ដែលអនុវត្តចំពោះបទល្មើសមជ្ឈឹមជាក់ស្តែងតម្រូវឱ្យមានស្ថានភាពមួយក្នុងចំណោមស្ថានភាពទាំងឡាយដូចតទៅនេះ ( មាត្រា១៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ) ។

-ជនសង្ស័យត្រូវបានគេទាន់នៅពេលកំពុងប្រព្រឹត្តបទល្មើស ឬត្រូវបានគេដេញតាមចាប់ប្រដាប់ប្រដាប់ប្រតឹង ដោយមានសម្រែកពីសាធារណជន ។

-ជនសង្ស័យបម្រុងរត់គេចវេះពីកន្លែងប្រព្រឹត្តបទល្មើស ។

-ជនសង្ស័យដែលចាប់ខ្លួនបានត្រូវនាំទៅជូនព្រះរាជអាជ្ញាក្នុងរយៈពេល៤៨ម៉ោង ក្រោយពីចាប់ខ្លួនជននេះ។ ព្រះរាជអាជ្ញាអាចសម្រេចឱ្យនាំខ្លួនទៅជំនុំជម្រះភ្លាមប្រសិនបើបទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។

កាលបើព្រះរាជអាជ្ញាជ្រើសរើសយកវិធីចោទប្រកាន់នេះមកអនុវត្តនោះព្រះរាជអាជ្ញា ត្រូវសួរយកចម្លើយជនដែលគេនាំទៅឱ្យខ្លួនដូចដែលមានចែងក្នុងមាត្រា៦៣ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ។ សួរយកចម្លើយរួចហើយព្រះរាជអាជ្ញាត្រូវបញ្ជូនសំណុំរឿងស៊ើបអង្កេតជាមួយនឹងកំណត់ហេតុសួរចម្លើយរបស់ខ្លួនទៅប្រធានតុលាការ ប្រធានតុលាការត្រូវចាត់តាំងចៅក្រមមួយរូប ដើម្បីជំនុំជម្រះរឿងនៅក្នុងថ្ងៃនោះតែម្តងចៅក្រមត្រូវអនុវត្តតាមមាត្រា ៦៤ ទៅ ៦៦ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ។

-ប្រសិនបើយល់ឃើញថា សំណុំរឿងមានលក្ខណៈពេញលេញហើយនោះចៅក្រមត្រូវជំនុំជម្រះរឿងនោះភ្លាមហើយក្នុងករណីដែលច្បាប់ចែងអោយផ្តន្ទាទោសដាក់ពន្ធនាគារអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន ដែលជាប្រការមួយធ្វើអោយមានការអនុវត្តន៍ភ្លាមនូវទោសដែលប្រកាស ។

-ប្រសិនបើយល់ឃើញថាសំណុំរឿងមិនទាន់ពេញលេញទេនោះចៅក្រមជំនុំជម្រះត្រូវលើកការជំនុំជម្រះទៅថ្ងៃក្រោយ ហើយនៅក្នុងករណីនេះចៅក្រមជំនុំជម្រះអាចឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នមិនឱ្យលើសពី៤ខែ។

-បើយល់ឃើញថា បទល្មើសដែលចោទប្រកាន់នោះមិនមែនជាបទល្មើសមជ្ឈឹមជាក់ស្តែងទេនោះចៅក្រមជំនុំជម្រះត្រូវបដិសេធចោលនីតិវិធីនេះ ហើយបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាវិញដើម្បីធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរអោយធ្វើការស៊ើបអង្កេតតាមមាត្រា៦០ ប៉ុន្តែចៅក្រមជំនុំជម្រះអាចជ្រើសរើសអនុវត្តតាមនីតិវិធីបញ្ជូនជនល្មើសទៅជំនុំជម្រះផ្ទាល់បាន កាលណាកំណត់ហេតុមានតម្លៃជាយថាភូត គឺភស្តុតាងលើជនជាប់ចោទមានគ្រប់គ្រាន់ ។

**<u>II-ការជ្រើសរើសវិធីចោទប្រកាន់៖</u>**

តាមការកត់សំគាល់របស់ក្រសួង ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបអង្កេតទៅចៅក្រមស៊ើបសួរស្ទើរតែជាស្វ័យប្រវត្តិ។

នៅក្នុងស្ថានភាពបច្ចុប្បន្នដែលខ្វះចៅក្រម និងដោយចំនួនរឿងកាន់តែកើនឡើងនោះការប្រតិបត្តិតាមរបៀបនេះនាំទៅដល់ការស្ទះការងារ និងកកស្ទះសំណុំរឿង ។

ក្នុងគោលដៅចង់ឱ្យការងារដំណើរការបានលឿន និងការពារសេរីភាពបុគ្គលឱ្យបានល្អនោះចាំបាច់ត្រូវតែប្រើវិធីសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងវិធីអនុវត្តតាមករណីបទល្មើសមជ្ឈឹមជាក់ស្តែងអោយបានច្រើនហើយបន្ថយវិធីសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបអង្កេត ការសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវតែយកមកប្រើនៅក្នុងគ្រប់ករណីទាំងអស់ដែលអាចធ្វើទៅបាន (ដូចជាការបរិហារកេរ្តិ៍ជាឧទាហរណ៍ ) ។

នីតិវិធីបទល្មើសព្រហ្មទណ្ឌជាក់ស្តែងត្រូវតែយកមកប្រើប្រាស់ឱ្យទូលំទូលាយ បុគ្គលដែលគេចាប់ខ្លួនបាននៅក្នុងពេលប្រព្រឹត្តបទល្មើសលួចដោយជាក់ស្តែងត្រូវតែចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះភ្លាម លើកលែងតែមានករណីពិសេសដោយឡែកដែលតម្រូវឱ្យធ្វើការស្រាវជ្រាវជាចាំបាច់ ។

ការនាំខ្លួនជនជាប់ចោទទៅធ្វើសវនាការភ្លាម ទាមទារឱ្យមានការចាត់តាំងឱ្យមានការប្រចាំការក្នុងចំណោមចៅក្រមអាសនៈ (ចៅក្រមជំនុំជម្រះ )។

ការសម្របសម្រួលល្អរវាងព្រះរាជអាជ្ញានិងមន្ត្រីនគរបាលយុត្តិធម៌ក៏ជាការចាំបាច់ដែរ ដូច្នេះបញ្ហាសំខាន់គឺព្រះរាជអាជ្ញាត្រូវតែបានទទួលដំណឹងយ៉ាងចាប់បំផុតអំពីការចាប់ខ្លួនជនល្មើសដែលធ្វើឡើងដោយនគរបាល ដើម្បីវាយតម្លៃស្តីពីលទ្ធភាពក្នុងការនាំខ្លួនជនជាប់ចោទទៅចំពោះមុខតុលាការ ហើយក្នុងករណីចាំបាច់ដើម្បីព្រះរាជអាជ្ញាតម្រង់ទិសដៅស៊ើបអង្កេតរបស់នគរបាល ក្នុងគោលបំណងធ្វើឱ្យសំណុំរឿងមានលក្ខណៈពេញលេញនិងទាន់ពេលវេលា ។ ដូច្នេះដើម្បីដោះស្រាយរឿងព្រហ្មទណ្ឌអោយបានឆាប់រហ័សនិងទាន់ពេលវេលាព្រះរាជអាជ្ញាត្រូវណែនាំទៅគ្រប់មន្ត្រីនគរបាលយុត្តិធម៌ ឱ្យចេះតាក់តែងកំណត់ហេតុ ដើម្បីស្រួលពិនិត្យវែកញែកកំណត់បទល្មើសឆាប់យល់ដឹងអំពីបទល្មើស អំពីភស្តុតាង និងវត្ថុតាង ។

ក្នុងកិច្ចការដែលទាក់ទងនឹងវត្ថុតាងនេះ ព្រះរាជអាជ្ញាត្រូវតែរៀបចំអោយមានសៀវភៅទទួលវត្ថុតាងមួយទទួលបន្ទុកដោយក្រឡាបញ្ជីអយ្យការម្នាក់អោយបានត្រឹមត្រូវ ។

ដើម្បីជួយរំលែកបន្ទុកដ៏ធ្ងន់ធ្ងររបស់ប្រធានតុលាការបច្ចុប្បន្ននេះ ក្នុងការអនុវត្តនីតិវិធីខាងលើព្រះរាជអាជ្ញាត្រូវចាត់ការរៀបចំកម្មវិធីជំនុំជម្រះសំណុំរឿងអាជ្ញាដោយខ្លួនឯង ពុំចាំបាច់ចៅក្រមជំនុំជម្រះជាអ្នករៀបចំទេ ។ ការ

រៀបចំកម្មវិធីជំនុំជម្រះនេះ ក៏ត្រូវមានការស្រុះស្រួលគ្នារវាងព្រះរាជអាជ្ញាជាមួយចៅក្រុមជំនុំជម្រះផងដែរពេលគឺនៅពេលធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ព្រះរាជអាជ្ញាត្រូវកំណត់ថ្ងៃ.ខែ.ឆ្នាំ ដាក់រឿងនេះជំនុំជម្រះអោយហើយជាស្រេច លុះសំណុំរឿងនេះទៅដល់តុលាការ ប្រធានតុលាការគ្រាន់តែចាត់តាំងចៅក្រុមឲ្យជំនុំជម្រះតាមថ្ងៃកំណត់របស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ដូច្នេះក្នុងសៀវភៅដាក់រឿងព្រហ្មទណ្ឌជំនុំជម្រះ ព្រះរាជអាជ្ញាត្រូវមានគ្រោងសម្រាប់កោះជំនុំជម្រះរឿងបញ្ជូនផ្ទាល់ ដែលត្រូវកោះជនល្មើស សាក្សីបំភ្លឺ ជនរងគ្រោះ តាមកំណត់ពេលវេលាដ៏សមរម្យជាមុន និងមានគ្រោងសម្រាប់ចុះរឿងជាក់ស្តែង ដែលអាចជូនទៅតុលាការជំនុំជម្រះភ្លាមនោះផង ។

សូមលោកព្រះរាជអាជ្ញា និងលោកចៅក្រុមទាំងអស់ ខិតខំយកចិត្តទុកដាក់អនុវត្តតាមការណែនាំខាងលើនេះឱ្យបានជាអតិបរមា និងមានប្រសិទ្ធិភាពខ្ពស់បំផុតតទៅ។ បើមានការមិនទាន់យល់ច្បាស់ត្រង់ចំណុចណា ឬចំពោះបញ្ហាពាក់ព័ន្ធផ្សេងទៀត សូមលើកសំណួរមកក្រសួង ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៥

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ
-ប្រធានតុលាការកំពូល
-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
-ប្រធានសាលាឧទ្ធរណ៍
-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
( ដើម្បីជូនជ្រាប )